
មរណភាពកសង្សារ
និពន្ធដោយ
ឃួង សួដា

# មរណភាពសង្ខារ

និពន្ធដោយ

ឃួន សូដា

# មរណភាពសង្សារ

និពន្ធដោយ ៖ យួង សុដា

ទូរសព្ទ ៖ 086 83 26 20

ហ្វេសប៊ុក ៖ Yuong So Da

គេហទំព័រហ្វេសប៊ុក : កម្រងស្មេរ/Collection Of Writers

*អ្នកអានមានសិទ្ធិដើម្បីថតចម្លង ផ្សព្វផ្សាយ ឬដកស្រង់បានដោយសេរី ដោយមិនចាំបាច់មានការអនុញ្ញាតពីអ្នកនិពន្ធ។ ប៉ុន្តែត្រូវគោរពនូវលក្ខខណ្ឌពីរយ៉ាង ទីមួយបញ្ជាក់ប្រភព និងទីពីរមិនយកទៅលក់ដូរ។*

*ស្នាដៃនេះ ត្រូវបាននិពន្ធឡើង សម្រាប់ចែកចាយដោយឥតគិតថ្លៃ ទៅកាន់អ្នកដែលចង់អាន និងបណ្ណាល័យមួយចំនួន ដើម្បីបម្រើប្រយោជន៍សាធារណជន និងសិស្សានុសិស្ស។*

# មាតិកា

បុព្វកថា

សេចក្តីថ្លែងអំណរគុណ

វគ្គ១ ជីវភាពក្រខ្សត់........................................១

វគ្គ២ ដំណៀលម្តាយអូន....................................៦

វគ្គ៣ វីរុសកំណាចកូរ៉ូណា................................១២

វគ្គ៤ មរណភាពសង្សារ....................................១៨

# បុព្វកថា

រឿង "មរណភាពសង្សារ" បង្ហាញពីខ្សែជីវិត និងស្នេហាប្រឌិតរបស់គូស្នេហ៍មួយគូ ក្នុងសម័យកាលនៃសង្គមខ្មែរ ក៏ដូចជាពិភពលោកទាំងមូល កំពុងឋិតក្នុងវិបត្តិកូវីដ (Covid 19) ឬមេរោគកូរ៉ូណា។ ថ្វីបើខ្ញុំមិនបានបដិសេធនូវប្រយោជន៍វិទ្យាសាស្ត្រទាំងស្រុង តែខ្ញុំពិតជាមានសេចក្តីតក់ស្លុត ចំពោះភាពរីកចម្រើនលឿនហួសនៃវិទ្យាសាស្ត្រសព្វថ្ងៃនេះ គឺហួសការអប់រំផ្នែកសីលធម៌ និងការរៀបចំសន្តិភាពសង្គមទៅទៀត។

ខ្ញុំសូមឧទ្ទិសស្នាដៃនេះ ចំពោះសោកនាដកម្មនៃពិភពលោកតែម្តង ហើយក៏សង្ឃឹមថា វិបត្តិនេះ នឹងសាបរលាបទៅវិញ។

បាត់ដំបង ២៤ ឧសភា ២០២០

ឃួង សុជា

# សេចក្តីថ្លែងអំណរគុណ

*សូមថ្លែងអំណរគុណ ដល់ក្រុមកម្រងស្នេរ និងមនុស្ស ជិតស្និទ្ធខ្ញុំទាំងអស់ ដែលតែងតែជួយផ្តល់យោបល់ល្អៗ និងជម្រុញទឹកចិត្តខ្ញុំអោយមានការពុះពារក្នុងការសម្រេច ឆន្ទះ និងកិច្ចការតែងនិពន្ធ!*

*សូមថ្លែងអំណរគុណ ដល់មិត្តអ្នកអានទាំងឡាយ ដែលតែងស្រឡាញ់គាំទ្រ និងលើកទឹកចិត្តខ្ញុំអោយបន្តការ ផ្សព្វផ្សាយស្នាដៃ។*

ឃួង សុខា

# វគ្គ ១ ជីវភាពក្រខ្សត់

បញ្ហាក្រពះ ជារឿងសំខាន់បំផុតមួយរបស់មនុស្ស ក្រៅពីបញ្ហានយោបាយ។ បើក្រពះស្រែកឃ្លានហើយ រាងកាយទាំងមូលនឹងរសេះរសោះ ហើយដៃជើងនឹងត្រូវខិតខំបំពេញកិច្ចការងារ ដើម្បីដូរយកបាយទឹកមកចម្អែតឱ្យក្រពះ។ ជាពិសេស ភាពក្រីក្រជំរុញមនុស្សឱ្យតស៊ូក្នុងឆាកជីវិតជាងភាពមានបានទៅទៀត។ ហេតុនេះហើយ “ គិរី ” ជាយុវជនកម្សត់មួយរូប ចាំបាច់ត្រូវរែកពុនកិច្ចការសព្វបែបយ៉ាង ដើម្បីចិញ្ចឹមលោកឪពុកដែលមានវ័យចំណាស់ទៅហើយ និងពិការជើងទាំងពីរក្រោយឆ្លងកាត់សង្គ្រាមខ្មែរក្រហម។ គេប្រកបរបរលក់ដំឡូងអាំង និងជួនកាលលក់ចេកអាំង ដោយជិះកង់សណ្ដោងរទេះកញ្ចាស់តូចមួយ វិលជុំវិញក្រុងបាត់ដំបង អស់រយៈពេលជាច្រើនឆ្នាំមកហើយ គឺតាំងតែពីនៅរៀនវិទ្យាល័យម្ល៉េះ។

បើនិយាយពីការរៀនសូត្រ គេបានបញ្ចប់សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ដោយជាប់និទ្ទេសមធ្យម។ តែបញ្ហាជីវភាពនេះឯងដែលរុញច្រានគេ មិនឱ្យបន្តទៅរៀនថ្នាក់បរិញ្ញាប័ត្របាន។ ខុសពីកូន

អ្នកមាន ដែលធំឡើងនៅលើគំនរទ្រព្យសម្បត្តិ គឺវីធំដឹងក្តីឡើងជាមួយនឹងតំណក់ញើស តំណក់ឈាមដែលហូរស្រោចក្រោមដំបូលស្បូវអ្នកក្រ។ តែទោះជាយ៉ាងណា គេមិនបានបញ្ឈប់ការសិក្សារបស់ខ្លួនឡើយ។ ពេលណា ទីណា វ័យណា ក៏អាចរៀនបាន ឱ្យតែយើងមានឆន្ទៈរៀនពិតប្រាកដ។ ចំណេះដឹងមិនដែលប្រកាន់មនុស្សទាល់តែសោះ។ ហេតុនេះ រាល់ពេលទំនេរ គឺវីតែងតែឆ្លៀតយកលុយកាក់ដែលសន្សំបានទៅទិញសៀវភៅទុកអាន ឬជួនកាលក៏ខ្ចីសៀវភៅពីមិត្តជិតស្និទ្ធពីរបីនាក់របស់គេ ដែលរៀននៅឯសាកលវិទ្យាល័យផ្សេងៗគ្នាក្នុងខេត្តបាត់ដំបង។

ក្រៅពីការអាន គឺការស្តាប់ជាផ្នែកមួយនៃការរៀនសូត្ររបស់គេផងដែរ។ លោកឪពុករបស់គេ ប្រៀបដូចជាគ្រូបង្រៀនដូច្នោះ។ ក្រោយពីអ្នកម្តាយចែកឋានទៅកាលគេនៅតូច គឺឪពុកដ៏មានគុណនេះហើយ ជាអ្នកទូន្មានប្រៀនប្រដៅ និងអប់រំអត្តចរិតរបស់គេឱ្យក្លាយជាមនុស្សថ្លៃថ្នូរ។ ក្នុងគ្រួសារដ៏កក់ក្តៅនេះ គឺមានតែឪពុកនិងកូន ពីរនាក់ប៉ុណ្ណោះ។ ផ្ទះរបស់ពួកគេ ឋិតនៅក្នុងភូមិទួលតាឯក។

ល្ងាចមួយនៃថ្ងៃអាទិត្យ ម៉ូតូឡានចរាចរទៅមកឥតដាច់សោះនៅក្នុងក្រុង។ គឺវីបានបញ្ឈប់កង់រទេះខ្លួននៅគល់ស្ពានថ្មចាស់ខាងកើត។ ក្លិនដ៏ឈ្ងុយឆ្ងាញ់នៃដំឡូងអាំង និងចេកអាំងនៅលើចង្ក្រានដែក

ពិតជាមិនអាចឱ្យអ្នកដំណើរដែលឆ្លងកាត់ទីនោះ ដាច់ចិត្តជិះហួសឡើយ យ៉ាងហោចណាស់ក៏ងាកសម្លឹងមើលបន្តិចដែរ។ សូម្បីតែអ្នកលក់ទឹកអំពៅ អ្នកលក់ម្ហូរ និងអ្នកលក់ប្រហិតនៅក្បែរនោះ ក៏ទ្រាំឃ្លានសឹងមិនបាន និងជួយទិញអ្នកកម្លោះដែរ។

- ពូអ្នកលក់! ដំឡូងអាំងមួយដុំថ្លៃប៉ុន្មាន? (នារីម្នាក់ស្រែកសួរពីក្រោយខ្នងអ្នកលក់)
- បាទ! មួយដុំ ៥០០៛! (គីរីតបដោយមិនបានមើលមុខអ្នកសួរ ព្រោះរវល់វេចខ្ចប់ឱ្យភ្ញៀវបួនប្រាំនាក់ដែលកំពុងចោមរោមទិញ)
- ចុះបេកអាំងវិញ? (នាងសួរបន្ត)
- មួយចង្កាក់១០០០៛!
- ចឹងខ្ញុំទិញទាំងអស់ មួយរទេះហ្នឹង!

គីរីភ្ញាក់ផ្អើលណាស់នឹងប្រយោគនេះ ក៏ងាកទៅមើលថាតើអតិថិជនណា អីក៏ថ្លើមធំម្ល៉េះ ហ៊ានមកម៉ៅដាច់អីចឹង។ ពេលនោះស្រាប់តែគេសើច ហើយឆ្លើយលេងជាមួយទៅវិញ ព្រោះជានារីដ៏ស្រស់ស្អាតម្នាក់ មានថ្ពាល់ខួចពីកំណើតគួរឱ្យស្រឡាញ់។

- យកទាំងអស់ចុះ! អត់គិតថ្លៃទេ! តែត្រូវដូរជាមួយនឹងថ្ពាល់មួយគូ! ហាសហា!

## មរណភាពសង្សារ

នាងក្រមុំរៀនបន្តិច តែក៏ដើរមកជិត និងយកកន្សែងបង់កជួយជូតញើសឱ្យគីរី។ អ្នកកម្លោះយើង មានកម្លាំងប្រឹស ដូចឡានចាស់ដែលទើបនឹងដូរម៉ាស៊ីនថ្មី។

- អូនទំនេរហើយឬថ្មើនេះ? (គីរីសួរទៅកញ្ញានោះ)
- ចាស! អូនទើបតែបោកខោអាវរួចអំបាញ់មិញ ក៏មកជួបបងភ្លាម។ (កញ្ញាឆ្លើយតប)
- ហេតុអីមិននៅផ្ទះអានសៀវភៅខ្លះទៅ មុន្នី?
- ទៅវិញក៏បានដែរ! (នាងងរង៉ក់បន្តិច ហើយចាប់កាន់សោរម៉ូតូបម្រុងនឹងបញ្ឆេះ)
- បងថាលេងទេតើ! ប្រញាប់តែខឹង! (គីរីលួងលោមសង្សារសំណព្វចិត្តខ្លួន)

នារីជាទូទៅ គឺបែបនេះ ឆាប់រំភើប ហើយក៏ឆាប់ងរង៉ក់ ឆាប់សើច ហើយក៏ឆាប់យំដែរ។ បើបុរសតាមមិនទាន់សភាពការណ៍ច្បាស់ជាបាក់មេឃបាក់ដីមិនខាន។ មុន្នីជាបុប្ផាមួយទងស្រស់ដាច់គេក្នុងភូមិអន្លង់វិល ដោយផ្ទះរបស់នាងនៅក្បែរវត្តអន្លង់វិលតែម្តង។ មុន្នីមានចរិតរឹងរូសបន្តិចមែន តែមានបេះដូងទន់ភ្លន់។ រាល់ពេលទំនេរពីរៀន និងកិច្ចការផ្ទះ មុន្នីតែងតែមកជួយកិច្ចការគីរី។ នាងមិនស្អប់ខ្ពើមអ្នកក្រដូចជាគីរីឡើយ គឺមានតែអាណិតស្រឡាញ់ថែមទៀត។

ល្ងាចនេះ មុន្នីជួយលក់ដូរជាមួយគីរីដល់ម៉ោង ៦ ។ រួចដៃ ពួកគេអង្គុយសាសង់គ្នា នៅលើស្ពានថ្មចាស់ដូចសព្វមួយដង។ សូរិយាធ្មេចភ្នែកលង់លក់សន្សឹមៗនៅខាងក្រោយអគារសាលាខេត្ត តែជើងមេឃនៅភ្លឺនៅឡើយ គឺចម្រុះទៅដោយពណ៌លឿង ក្រហម ទឹកក្រូចនិងស្វាយ ដែលហាក់ដូចជាគំនូរដ៏ស្រស់ស្អាតមួយផ្ទាំង។ មុន្នីផ្អែកលើស្មាគូសង្សារ យ៉ាងមានសេចក្ដីសុខ ក្រោមស្រមោលនៃសត្វត្រចៀកកាំមួយហ្វូង ដែលហោះវិទ្ធលឆ្វាត់ជុំវិញស្ពានថ្មចាស់។ ទីនេះជាឋានឱសថ និងជាឋានលាក់បាំងសុភមង្គលនៃគូស្នេហ៍មួយគូ។ ចំណែក ស្ទឹងសង្កែ តែងហូរនាំពាក្យពេចន៍ស្នេហារាល់រដូវកាល ទៅប្រកាសប្រាប់ដល់អស់ធម្មជាតិ នៅបឹងទន្លេសាប។

# វគ្គ ២ ដំណៀលម្ដាយអូន

មួយ ឆ្នាំក្រោយមក គឺនៅដើមឆ្នាំ២០២០។ ស្នេហា រវាងគិរី និងមុន្នីស្និតរមួតចូលគ្នាលេះមិនដាច់។ តែគេមិនទាន់ដឹងនៅឡើយទេថា តើព្យុះវាសនារបស់អ្នកទាំងពីរនឹងបក់ទៅទិសណានៅឡើយ។ កម្លោះអ្នកក្រ ត្រដរស្នេហ៍ក្រមុំអ្នកមាន គឺពិតជាមិនងាយស្រួលនោះទេ។ នេះជារឿងដែលគិរីដេកព្រួយបារម្ភជានិច្ច។

ព្រឹកមួយជាថ្ងៃសុក្រ មុន្នីពាក់អាវស សន្ទុះក្នុងសំពត់ខ្មៅត្រឹមជង្គង់ មើលទៅមិនចាញ់សម្រស់និស្សិតស្រីជប៉ុនឡើយ។ តែនាងគឺជានិស្សិតនៃសាកលវិទ្យាល័យបាត់ដំបងទេ។ នៅពេលនាងឡើងជិះម៉ូតូម៉ាកClickពណ៌សរបស់នាងថែមទៀតនោះ គឺរឹតតែសមណាស់ទៅទៀត។ បុរសណាក៏តែងតែតាមលួចសម្លឹងមើលនាងដែរ។ ប៉ុន្តែព្រឹកនេះ នាងចូលមិនទាន់ដល់កន្លែងផ្ញើម៉ូតូផង មិត្តនាងមួយក្រុមមកជិតប្រាប់ថាគ្រូរវល់អស់ហើយ។ ថ្នាក់នាងទំនេរ ដូច្នេះ នាងគិតថានឹងណាត់គិរីទៅដើរលេងនៅបាណន់ម្ដង។

គិតហើយ នាងក៏បែរក្បាលម៉ូតូត្រឡប់ទៅផ្ទះវិញ ដើម្បីផ្លាស់ឯកសណ្ឋាននិស្សិតចេញ។ តាមផ្លូវវង្វេងមូលព្រាបស នាងចេះតែញាក់ភ្នែកឆ្វេងមិនឈប់ ហើយចេះតែចាប់របស់នេះរបស់នោះមិនសូវជាប់នឹងដៃសោះ។ នាងលួចសង្ស័យក្នុងចិត្ត ថាវាជាប្រផ្នូលមិនល្អ តែក៏ព្យាយាមបំភ្លេចអារម្មណ៍បែបនេះចេញ ព្រោះថានាងជិតទៅដើរលេងហើយ។

លុះតុបតែងផាត់មុខ អប់ប្រេងម្សៅហើយ នាងក៏ឡើងម៉ូតូទៅយកគីរីនៅឯផ្ទះរបស់គេ។ គីរីត្រូវខកខានលក់ដូរមួយថ្ងៃ ដើម្បីនាំនាងច្រម៉ក់តូចទៅកម្សាន្តកាយ។ ពីព្រឹកទល់ល្ងាច ពួកគេសប្បាយជាមួយគ្នាយ៉ាងអស់ដៃ។ ក្រៅពីឡើងមើលប្រាសាទ គឺពួកគេជិះឡូរី ហើយអង្គុយញ៉ាំសង្វាក់អាំង និងដូងត្រជាក់។ រូបថតជាច្រើនសន្លឹក ត្រូវបានផ្ដិតជាប់នៅក្នុងទូរសព្ទ។ អ្នកដំណើរផ្សេងទៀត មិនថានៅលីវ ឬមានគ្រួសាររួចក្ដី លួចច្រណែននឹងភាពផ្អែមល្ហែមនៃគូសង្សារនេះណាស់។

លុះព្រះអាទិត្យរៀបនឹងអស្ដង្គតទៅហើយ ពួកគេក៏ត្រឡប់មកផ្ទះវិញ។ ជាអកុសល ឡានមួយគ្រឿងបានបើកជែងគេឯងយ៉ាងលឿនដូចរន្ទះ មកចំពីមុខម៉ូតូអ្នកទាំងពីរ។

- ប្រាវ! (សូរសំឡេងមួយលាន់ឮដូចរន្ទះជាប់ផ្លូវសាធារណៈ)

**មរណភាពសង្សារ**

គីរីដែលជាអ្នកកាន់ចង្កូត ខំគេចចេញពីឡាននោះ ក៏ជ្រុលធ្លាក់ចូលទៅក្នុងប្រឡាយរីងទឹកមួយដែលនៅជាប់មាត់ថ្នល់។ កង់ម៉ូតូវិលខ្វាល់ដូចស្លាបកប៉ាល់ ហើយតួម៉ូតូកិនជើងមួយចំហៀងរបស់គីរី ចំណែកមុន្នីខ្ទាតចេញពីម៉ូតូបន្តិច ហើយប្រឡាក់ភក់ និងរបួសដៃជើងគួរសម។ សំណាងហើយដែលមានស្មៅ និងវល្លិខ្លះៗជួយទ្រ មិនដូច្នោះច្បាស់ជាអាសន្នធំជាងនេះ។ ចំណែក អ្នកជិតខាងនៅក្បែរនោះនាំគ្នាយកអាសារ ដោយជួយគ្រាអ្នកទាំងពីរ និងលើកម៉ូតូចេញពីប្រឡាយ។ គេបានត្រឹមតែអាណិត មិនដឹងជួយដោះស្រាយវិធីណាទេ ព្រោះឡានដែលបង្កហេតុវិញ ដាក់មេប្រូចទៅហើយ រកស្រមោលមិនឃើញឡើយ។

រយៈពេលប្រហែលកន្លះម៉ោង ផ្គរមេឃចាប់ងងឹតទៅៗ។ បន្ទាប់ពីលាងរបួស និងរុំក្រណាត់បន្តិចបន្តួច ពួកគេមិនអាចបង្អង់យូរទៀតទេ។ គីរីត្រូវជូនសង្សារទៅផ្ទះ។ មុន្នីឱបចង្កេះបុរសសម្លាញ់ចិត្ត ដោយសេចក្ដីតក់ស្លុត ញ័រសាច់មិនទាន់បាត់នៅឡើយ។ អ្វីដែលនាងភ័យខ្លាចជាឧបទ្ទវហេតុនោះ គឺអ្នកផ្ទះរបស់នាង។

មិនយូរប៉ុន្មាន កង់ម៉ូតូបានវិលទៅដល់គោលដៅ។ វូស! វូស! វូស! វូស! សំឡេងឆ្កែបីបួនក្បាលព្រុសបណ្ដាក់គ្នាមិនឈប់ ចេញពីច្រកទ្វាររបងផ្ទះ។

- ជូនអូនត្រឹមហ្នឹងហើយ! សំណាងល្អបងសម្លាញ់!
- បាទ! ឆាប់ចូលសម្រាកណាយប់ហ្នឹង!
- ចាស! អូនដឹងហើយ។ បងបានអ្វីជិះទៅផ្ទះវិញ?
- បងនឹងរកតុក។ ឬម៉ូតូឌុបជិះ។ មិនអីទេណា! បងទៅសិនហើយ!
- ចាសបង! ថែខ្លួនផង!

លុះមុន្នីបណ្ដើរម៉ូតូខ្លួនចូលផ្ទះ បានតែប្អូនប្រាំជំហាន នាងក៏ទន់ជើងភ្លាត់ដួលស្ទ្បាបពីលើម៉ូតូ។ គិរីដែលមិនទាន់ទៅណាឆ្ងាយពេលងាកក្រោយឃើញដូច្នោះ ក៏ប្រញាប់មកជួយបីនាង។ ភ្លាមនោះគ្រួសាររបស់មុន្នី ដែលក្រឡេកឃើញ មានការភ្ញាក់ផ្អើលព្រោះឃើញបុរសមិនធ្លាប់ស្គាល់មកលើកបីសាច់ញាតិខ្លួន។ គឺពេលនេះហើយដែលអ្នកទាំងពីរមិនអាចបិទបាំងជិត អំពីការលួចនាំគ្នាដើរលេងពេញមួយថ្ងៃ ពិសេសទំនាក់ទំនងស្នេហាដែលកំពុងតែពេញអណ្ដាតភ្លើង។ ម្ដាយរបស់មុន្នី ជាមនុស្សដែលមិនពេញចិត្តទាល់តែសោះចំពោះគិរី។ គាត់សម្លឹងមើលលើមើលក្រោម និងសួរដេញដោលចាក់ដោតនូវសម្ដីជាច្រើនឃ្លា។

- មុន្នីកើតអីកូន? (ម្ដាយសួរទៅកូនស្រី ហើយមើលរបួសដែលនៅថ្មីៗ)

- កូនដួលម៉ូតូតិចតួចទេម៉ាក់ ព្រោះឡានដែលមកពីមុខ វាបើកអត់មើលមនុស្ស។
- ហើយខាងណោះត្រូវជាអីនឹងមុន្នីកូនខ្ញុំ? (គាត់សួរទៅគីរីវិញម្ដង)
- ខ្ញុំជាមិត្តជិតស្និទ្ធនឹងមុន្នី។ អ្នកមីង!
- មិត្តជិតស្និទ្ធ ឬក៏សង្សារ? (គាត់សួរដោយកែវភ្នែកកំហឹង)
- ជាមិត្តកូនមែនតើម៉ាក់! (មុន្នីលូកមាត់)
- កូនឯងកុំមកលាក់បាំងនឹងម៉ាក់! ម៉ាក់ប្រាប់ប៉ុន្មានសាហើយថាមិនឱ្យកូនមានស្នេហាជាមួយអ្នកណាអ្នកណីទេ។ ម៉ាក់ចេះរៀបចំឱ្យកូនហើយ។ គេកូនអ្នកលក់មាស សង្ហាក៏សង្ហា មានក៏មាន ម៉ាក់ណែនាំហើយ ម៉េចក៏មិនចេះទាក់ទង។ ក្រែងលោតែរហាមស៊ីអំបិលស៊ីប្រហុករាល់ថ្ងៃទៅ។

គាត់ស្ដីបន្ទោសចំពោះកូនស្រី ដើម្បីជៀមដាមឱ្យកម្លោះកូនអ្នកក្រ។ អ្វីៗហាក់តានតឹងណាស់នៅក្នុងពេលនេះ ។ គូសង្សារទាំងពីរបានត្រឹមតែនៅស្ងៀមសិន ស្ដាប់ម្ដាយបញ្ចេញកំហឹងឱ្យអស់ពីទ្រូង។ អស់បួនប្រាំដង្ហើម គាត់ចាប់បន្តទេសនា។

- អ្នកកម្លោះ កុំមកពាក់ព័ន្ធជាមួយកូនស្រីខ្ញុំទៀត។ កូនមីងមានគូអនាគតរួចហើយ។ គូអនាគតមុន្នីជាត្រកូលអ្នកមាន មិន

មែនត្រកូលអ្នកស្រែចំការទេ។ ទៅផ្ទះវិញចុះក្មួយ! ឈប់នាំកូនមីងដើរលេងទៀត! មីងប្រាប់មុនឱ្យហើយ!

- បាទ! អ្នកមីង! ខ្ញុំជម្រាបលាសិនហើយ!

មុន្នីចង់ចេញមុខការពារគិរីណាស់ តែនាងដឹងថា កាន់តែតមាត់ជាមួយម្ដាយ គាត់កាន់តែខឹងខ្លាំងឡើង នាំឱ្យរឿងរឹតតែធំ។ ដូច្នេះមានតែលួចឈឺចាប់ជំនួសសង្សារខ្លួន។ ចំណែកគិរីស្ទើរថប់ដង្ហើមក្អួតឈាមនៅមួយកន្លែង តែគេខំទប់ជំហរចាកចេញពីកន្លែងមើលងាយមើលថោក។ រនាំងវណ្ណៈ រារាំងស្នេហាពួកគេមិនឱ្យជួបគ្នាងាយៗឡើយ។

# វគ្គ ៣ វីរុសកំណាចកូរ៉ូណា

ចាប់ពីចុងឆ្នាំ២០១៩ មកទល់នឹងដើមឆ្នាំ២០២០នេះ ប្រហែលជាពេលាមួយ ដែលចង្រៃបំផុតរបស់ពិភព លោក។ ក្រៅពីភ្លើងឆេះព្រៃអាម៉ាហ្សូន ពិភព លោកក៏កំពុងតែជួបនឹងវិបត្តិដ៏ធំមួយទៀតគឺ វីរុសកូរ៉ូណា (ឬកូវីដ ១៩)។ វីរុសនេះផ្ទុះចេញពីតំបន់វូហាន ប្រទេសចិន ហើយរីករាល ដាលយ៉ាងរហ័សទៅកាន់ប្រទេសផ្សេងៗទៀត។ ផលលំបាកទាំងនេះ បើស្ដាប់មើលទៅ វាអាចមកពីមូលហេតុនានា ដោយព័ត៌មានខ្លះថា មេរោគចម្លងពីសត្វមកមនុស្ស ហើយព័ត៌មានខ្លះទៀត គឺប្រទេសមួយ ចំនួន ដូចជាមហាអំណាចសហរដ្ឋអាមេរិកជាដើម បានចោទចិនថា មានមហិច្ឆតាបង្កើតអាវុធជីវសាស្ត្របែបនេះ ដោយបែកធ្លាយចេញពី មន្ទីរពិសោធជាដើម។ តែបើសរុបជារួមទៅ អាចនិយាយថាវា បណ្ដាលមកពីវិទ្យាសាស្ត្រដើរហួសសីលធម៌មនុស្ស។ មេរោគដ៏កាច សាហាវភាគច្រើន រួមទាំងអាវុធប្រល័យលោកទាំងអស់ តែងកើត ចេញពីស្នាដៃមនុស្សផ្ទាល់ ឬជាផ្លែផ្កានៃវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្រ អាចជួយមនុស្ស ហើយក៏អាចបំផ្លាញមនុស្សដូចគ្នា។ វិទ្យាសាស្ត្រដើរ

កាន់តែលឿន ពិភពលោករឹតតែគ្រោះថ្នាក់។ វិទ្យាសាស្រ្តដែលប្រាសចាកសីលធម៌ គឺជាវិនាសកម្ម។ គ្មានអ្វីដែលបំផ្លាញផែនដីជាង៍ភាពអាក្រក់របស់មនុស្សនោះទេ ហេតុនេះ ការអប់រំសីលធម៌នៅតែសំខាន់មិនថា សម័យកាលណា ហើយសាសនានៅតែចាំបាច់សម្រាប់ការទូន្មានមនុស្ស។

នៅថ្ងៃ១៦ មីនា ឆ្នាំ២០២០ ប្រទេសខ្មែរបានប្រកាសបិទសាលារៀន និងការជួបជុំទាំងអស់ ដើម្បីបង្ការការឆ្លងវីរុសក្លូរ៉ូណា។ គេបិទក្រោយបុណ្យទន្លេចប់ភ្លាម នៅបាត់ដំបង។ ប៉ុន្តែ ថ្វីបើសិស្សសាលាផ្អាករៀន អ្នកមានផ្អាកធ្វើការ ក៏អ្នកស្រែចំការ និងអ្នកផ្សារខ្លះមិនអាចដេកផ្ទះបានស្រួលដែរ។ ពួកគេរកបានមួយថ្ងៃ រស់មួយថ្ងៃ ឬថ្ងៃខ្លះមិនចង់រស់ផង។ ចុះទម្រាំតែមិនរកស៊ីទៀត តើបានចំណូលមកពីណាមកចិញ្ចឹមគ្រួសារ? ដូច្នេះ ពួកគេនៅតែចេញរកស៊ី ទោះប្រឈមនឹងសេចក្តីស្លាប់ក៏ដោយ ទោះខុសនឹងការហាមប្រាមក៏ដោយ ព្រោះថា ការដេកស្ងៀមក៏ស្លាប់ដូចគ្នា គឺស្លាប់ដោយសារអត់បាយ។ មេរោគនេះ អាចរស់នៅក្នុងខ្យល់ អាចតោងនៅលើវត្ថុផ្សេងៗដែលអ្នកជំងឺប៉ះពាល់ បើនរណាមិនប្រយ័ត្ន ច្បាស់ជាឆ្លង។ សូម្បីតែប្រទេសដែលមានប្រព័ន្ធសុខាភិបាលខ្ពស់ ក៏នៅតែឆ្លងជំងឺនេះ ចុះទម្រាំតែប្រទេសខ្មែរ ដែលមានប្រព័ន្ធសុខាភិបាលអន់ថយទៀតនោះ

តើយ៉ាងណាទៅវិញ? ប្រទេសគេបិទដើងយន្តហោះពីបរទេស ពិសេសចិន តែនៅខ្មែរឯណោះស្វាគមន៍ជានិច្ច មិនថាទេសចរចិនក៏ដោយ។ ទីបំផុត មេរោគក្លូរ៉ូណាលុកលុយស្រុកខ្មែរទាល់តែបាន ដោយសារតែការធ្វេសប្រហែសមើលស្រាលស្ថានការណ៍ និងភាពអាត្មានិយមគិតតែពីប្រយោជន៍រកស៊ីនៃពួកអ្នកធំ មិនគិតដល់រាស្ត្រ។ គិតសព្វៗទៅ ជីវិតពលរដ្ឋខ្មែរហាក់ផុយស្រួយបំផុត បើធៀបទៅ គឺជាជីវិតដែលគេចងព្យួរនៅលើមាត់ជ្រោះគ្រប់នាទី។

ថ្លៃងពីគីរីវិញ ជារាស្ត្រខ្មែរក្រីក្រម្នាក់ដូចគេឯងដទៃ មិនដឹងជាបានលុយឯណាមកដេកស៊ីដូចអស់លោកអ្នកធំទាំងឡាយ បើមិនខំធ្វើការងារបន្ត។ គេយកក្រមាជូតញើសដែលហូរសស្រាក់ដូចគេចាក់ទឹក។ គេមិនអាចបញ្ឈប់កង់រទេះ ដែលកំពុងតែអូសកាត់ក្រុងបាត់ដំបងបានឡើយ ទោះជាមេឃក្តៅប្រេះក្រហែងយ៉ាងណា។ ជិតចូលឆ្នាំទៅហើយ តែស្ងាត់ប្លែកខុសពីឆ្នាំមុនៗ។ កម្មវិធីសង្ក្រាន្ត តាមខេត្ត តាមសាលារៀនមួយចំនួនត្រូវលុបចោល។ មនុស្សធ្លាប់តែដង្ហែគ្នាកកកុញ លេងគប់ទឹក រាំរែក ផឹកស៊ី កន្លែងខ្លះលេងល្បែងប្រជាប្រិយ តែឥឡូវមនុស្សខ្លាចគ្នាដូចZoombiesក្នុងភាពយន្ត។ ផាកទៅណាក៏មិនសូវមានមនុស្សសោះ។ តូបផ្សារភាគច្រើនបិទអស់រលីង។ ទីប្រជុំជនបាត់ដំបងប្រែជាស្ងាត់ជ្រងំដូចទីក្រុងខ្មោច។ គីរីលក់មិនសូវ

ដាច់ដូចមុនទេ ហើយអ្នកលក់ដូរគ្រប់កន្លែងទាំងអស់ សុទ្ធតែត្អូញត្អែរគ្រប់គ្នា។ អ្នកខ្លះជំពាក់លុយគេវ៉ាន់ក ហើយខ្លះទៀតត្រូវខាងធនាគារ និងគ្រឹះស្ថានមីក្រូមួយចំនួន បង្ខំឱ្យលក់ទ្រព្យសង ឬយកអ្វីមួយទៅបញ្ចាំ។ គីរីវិញក៏ចាប់ផ្ដើមចេះជំពាក់អ្នកស្គាល់គ្នា ដើម្បីដោះទុក្ខមួយគ្រាសិន។ គីរីពាក់ម៉ាស់យ៉ាងកញ្ចាស់មួយ ដើម្បីការពាររោគកូរ៉ូណា ហើយម៉ាស់នេះ បោកគក់ប្រើ ជិតមួយខែមកហើយ ដ្បិតម៉ាស់ឡើងថ្លៃ ហើយអាល់កុលលាងដៃក៏ឡើងថ្លៃដូចគ្នា។ គេធ្លាប់ទិញម៉ាស់ធម្មតាពីរតម្លៃ ៥០០៛ តែពេលនេះម៉ាស់ធម្មតាមួយសោះ តម្លៃដល់ទៅ ៤០០០៛ ទៅ៥០០០៛។ ម៉ាស់១ស្មើអង្ករ២គីឡូក្រាម ចឹងសួរថាអ្នកក្រគួរទិញអង្ករ ឬទិញម៉ាស់? ម្យ៉ាង ម៉ាស់នេះ បើបោកគក់ម្ដងពីរដងហើយ វាក៏លែងមានប្រសិទ្ធភាពទៀតដែរ។ ដូច្នេះមានន័យថា ម៉ាស់របស់គីរី និងម៉ាស់របស់អ្នកក្រដទៃទៀត មិនបានជួយអ្វីទេ បើមេរោគឆ្លងនោះ។ ម៉ាស់និងអាល់កុលឡើងថ្លៃ តែអ្វីផ្សេងចុះថោកស្ទើរតែទាំងអស់។ ម្នាក់ៗដាច់បាយគ្រប់គ្នា បែរជាអ្នករកស៊ីកោរគេរឿងម៉ាស់និងអាល់កុលកើតអ្នកមានសឹងគ្រប់គ្នា ហើយអ្នកខ្លះលួចលក់អាល់កុលក្លែងក្លាយទៀត។ ឱ! ហ៊្ន! ខ្មែរយើង! ចុះបើឆ្លងរោគគ្រប់គ្នាទៅ អ្នកលក់ទាំងអស់ហ្នឹង គាត់សង្ឃឹមរវេចលុយយកទៅចាយឯណាវិញ?

មិនយូរប៉ុន្មាន គិរីចាប់ផ្ដើមមានអាការៈមិនស្រួលសោះ។ ខ្លួនគេហាក់ឡើងកម្ដៅជាងធម្មតា តែគេនៅអូសរទេះលក់ធម្មតា ព្រោះតែជីវភាពខ្វះខាត។ ល្ងាចមួយ ដើមខែមេសា ផ្ទៃមេឃគ្រប ដណ្ដប់ដោយពពកធំៗក្រាស់។ ខ្យល់ងងឹតដូចយក្សចុះមកស៊ីមនុស្ស។ ព្យុះបញ្ចេញឫទ្ធិអំណាចក្ដួចត្របាញ់ដួលបាក់ដើមឈើ បង្គោលភ្លើង និងបង់អង្គុយនៅតាមសួនសាធារណៈ។ ភ្លៀងបង្អុរចុះមកដូចគេខឹង ពីថ្ងៃណា។ ផ្ទះខ្លះលិចទឹកចូលតាមមាត់ទ្វារ ខ្លះលិចភ្លៀងពីដំបូល ហើយផ្ទះខ្លះបើងទាំងដំបូល។ ម៉ូតូនៅមុខផ្ទះប្រជាពលរដ្ឋខ្លះ ដួលគរ ជើងគ្នា។ រទេះដំឡូងអាំងរបស់គិរីអូសចូលក្នុងវត្តសឹងតែមិនទាន់ ចំណែកខ្លួនគេរអិលដួលបោកក្បាលទៅលើថ្មមួយ។ ឈាមហូរចេញ មកតិចៗលាយនឹងភ្លៀងភក់ប្រលាក់សក់ក្បាល។ គិរីស្រែកអូយបាន តែមួយម៉ាត់ ក៏សន្លប់បាត់មាត់ឈឹង។ ទីនោះស្ងាត់ ហើយមនុស្សមួយ ចំនួនតូចដែលឆ្លងកាត់ឃើញ មិនទាន់ហ៊ានចូលជួយទេ ព្រោះខ្លាច ឆ្លងកូរ៉ូណា តែបន្តិចក្រោយមក ព័ត៌មាននេះផ្សាយពេញហ្វេសប៊ុក។

មុន្នីដែលខានចេញពីផ្ទះជិតកន្លះខែទៅហើយ សែនទឹករពូកគិរី ក្រៃលែង។ គេចង់ចេញដែរតែម្ដាយហាម ព្រោះជំងឺរាតត្បាតពេក។ លុះមកអូសហ្វេសប៊ុក ឃើញរូបបុរសម្នាក់ដេកដួលសន្លប់ក្បែររទេះ ដំឡូងអាំង ក៏ដឹងភ្លាមថាជាបុរសសំណព្វចិត្តខ្លួន។ នាងក៏ប្រញាប់

ប្រញាប់ចេញម៉ូតូទៅ តែខកពេលទៅហើយ។ ឡានពេទ្យទើបតែចេញផុតពីកន្លែងកើតហេតុ។ នាងស្ដុតចិត្ត ហើយសួរមនុស្សម្នាដែលនៅក្បែរនោះ។ បន្តិចក្រោយមក នាងក៏ទៅដល់មន្ទីរពេទ្យមួយក្នុងក្រុងបាត់ដំបង។

# វគ្គ ៤ មរណភាពសង្សារ

គុក និងមន្ទីរពេទ្យ មានសភាពប្លែកគ្នាយ៉ាងណាទៅ ចំពោះអ្នកជំងឺដែលដឹងថាខ្លួនជិតស្លាប់នោះ? វាប្រៀបដូចជាអ្នកទោសម្នាក់ ដែលគេជិតយកទៅសម្លាប់ចោលដូច្នោះ។ ទន្ទឹមនឹងរបួសក្បាលដែលបុកនឹងថ្ម គិរីក៏ត្រូវបានក្រុមគ្រូពេទ្យធ្វើតេស្តឃើញមានដុំមហារីកក្នុងណាផងដែរ។ គេត្រូវបានដាក់ឱ្យនៅបន្ទប់មួយដាច់ដោយឡែក។

មុន្នីអន្ទះសារណាស់។ នាងដើរទៅដើរមកក្នុងមន្ទីរពេទ្យដូចមនុស្សវិកលចរិត។ នាងអង្វរពេទ្យយ៉ាងណា ក៏មិនអាចចូលជួបបានដែរ។ ចុងក្រោយ ពេទ្យយល់ព្រមឱ្យនាងជួបតាមទូរសព្ទ។ ពួកគេនិយាយគ្នាដោយភាសាទឹកភ្នែក។

- បងសម្លាញ់!
- អូនមុន្នី!
- បងសុខទុក្ខយ៉ាងណាហើយ?
- បងមិនអីទេ! ចុះអូនវិញ? បងខានមើលមុខសង្សារបងយូរថ្ងៃហើយ។ សង្ស័យតែអាក្រក់ជាងមុនហើយមើលទៅ!

- នៅមកលេងសើចនឹងអូនកើតទៀត! បងឯងនេះ! អូនមិនអីទេ។ គិតតែខ្លួនបងទៅ!
- ជាតិនេះ ដឹងតែមិនរស់ហើយ។ អូនកុំគិតច្រើនពេកអី!
- កុំនិយាយចឹង! ប្រយ័ត្នអូនវាយបង! បងត្រូវតែរស់ដល់ចាស់ជាមួយនឹងអូន។ បងធ្លាប់សន្យាថាម៉េចខ្លះ? នៅចាំទេ?
- បងចាំទាំងអស់ ចាំគ្មានភ្លេច ចាំលុះដង្ហើមចុងក្រោយ។
- អូននឹកបងណាស់។ គិរី! បងមានដឹងទេ? (នាងយំខ្លាំងឡើង)
- បងក៏ដូចគ្នា! នឹកអូនស្ទើរដាច់ខ្យល់មុនជំងឺទៅហើយ។
- បងត្រូវតែឆាប់ជាណា! ឆាប់មកជួបអូន! កុំទុកអូនឱ្យកំព្រាតែម្នាក់ឯង!
- បាទ! បងសន្យា!

ពេលវេលាឆាប់រហ័សណាស់ សម្រាប់មនុស្សដែលលាគ្នាជាលើកចុងក្រោយ។ ស្នេហាមួយដែលព្រាត់គ្នាទាំងមិនបានជួបមុខ គឺពិតជាគួរឱ្យសោកសង្រេងរកអ្វីផ្ទឹមពុំបាន។ មុន្នីយំដូចកូនក្មេង ពេលដែលឮថាគិរីផុតដង្ហើម។ គ្រូពេទ្យបានព្យាយាមយ៉ាងអស់ពីចិត្តពីថ្លើមហើយ តែថ្នាំព្យាបាលមិនទាន់មាននរណារកឃើញនៅឡើយ។ នៅប្រទេសខ្លះទៀត ស្លាប់ដូចខ្មោចឆ្កែ។ នាងអាណិតស្ទើរខ្លោចចិត្ត។

សូម្បីតែសាកសព ក៏គេយករុំក្រណាត់យ៉ាងជិត ហើយយកទៅបូជាភ្លើងនៅទីវាលមួយដែលគេទុកចោល ឆ្ងាយពីប្រជុំជន ដើម្បីការពារការឆ្លងរីករាលដាលនៃមេរោគក្សរ៉ូណា។ ព័ត៌មាននេះត្រូវបានគេលាក់យ៉ាងជិត ព្រោះចៀសវាងភាពចលាចលកើតឡើង។

ឱ! បុរសកម្សត់ម្នាក់ស្លាប់ទៅហើយ ក៏នារីជាទីស្រឡាញ់របស់គេមិនអាចមើលបានទៀត។ ក្សរ៉ូណាដ៏កំណាចឥតមេត្តាអើយ! អ្នកឯងនេះនាំហាយនភាពដល់គេឯងច្រើនណាស់។ បើសិនជាអ្នកឯងពុំមែនជាមេរោគដែលគេមើលមិនឃើញ ហើយមានរូបរាងឃើញច្បាស់ ទោះធំប៉ុណ្ណា ប៉ុនដំរី ឬប៉ុនដើមត្នោត ក៏ខ្ញុំមិនខ្លាចនឹងប្រយុទ្ធនឹងអ្នកឯងដែរ។ ខ្ញុំសុខចិត្តស្លាប់ ឱ្យតែបានតទល់ ក៏ខ្ញុំនេះអស់ចិត្ត។

មុន្នីបួងសួងដល់អស់ទេព្តា ដល់គុណព្រះរតនត្រ័យ និងបុណ្យកុសលទាំងឡាយដែលធ្លាប់សាង ដើម្បីផ្សងជួបគីរីនៅជាតិក្រោយ។ នាងលេបបាយលែងចូល ធ្វើអ្វីលែងកើត ល្ហិតល្ហៃកម្លាំងកំសោយ ដកតែដង្ហើមក៏មិនចង់ដល់គ្នា។ មួយប៉ប្រិចភ្នែកសោះ ខ្លួនប្រាណនាងស្គមដូចកុក។ ខោអាវដែលធ្លាប់ពាក់សម ពេលនេះរលុងរយ៉ាយ។ គ្រួសារនាងបារម្ភណាស់ ហើយចេះតែឆ្ងល់ពីមូលហេតុដែលនាងធ្វើបាបខ្លួនដូច្នេះ។ តែនាងនៅស្ងៀមលែងនិយាយរកនរណាទាំងអស់។ នាងដេកយំទាល់តែហើមភ្នែក ហើយគេងលក់ដល់ថ្ងៃត្រង់ទើបភ្ញាក់។

តែចិត្តមួយនៅនឹកអាសូរដល់ឪពុករបស់គីរីដែលឥតទីពឹង។ ដូច្នេះនាងកើតគំនិតមួយគឺខំរស់ ខំហូបបាយឡើងវិញ។ រៀងរាល់អាទិត្យនាងឧស្សាហ៍យកបាយម្ហូបទៅជូនឪពុកគីរី និងលុយកាក់បន្តិចបន្តួចដែលនាងសន្សំ ដោយមិនឱ្យអ្នកផ្ទះខ្លួនដឹងឡើយ។ ប៉ុន្តែជួបមុខឪពុកគេពេលណា នាងចេះនឹកដល់កូនប្រុសគេរហូត។

នាងបិទភ្នែកដេក យល់សប្តិឃើញតែគីរី ហើយបើកភ្នែកឡើងចេះតែច្រទ្បំថា គីរីកំពុងតែលក់ដំឡូងអាំងកណ្តាលថ្ងៃក្តៅ។ ថ្ងៃខ្លះនាងជិះម៉ូតូទៅកន្លែងដែលធ្លាប់រួមអនុស្សាវរីយ៍ ដូចជាស្ពានថ្មចាស់ស្ពានថ្មថ្មី មុខសាលាខេត្ត មុខវត្តនានាតាមដងស្ទឹងសង្កែ តាមដងវិថីមួយចំនួន រួមទាំងប្រាសាទ។ នាងអង្គុយមើលថ្ងៃលិចតែម្នាក់ឯងរហូតទាល់តែយប់បាំងភ្នែកងងឹតលែងយល់។ សន្ទៀមត្រជាក់បានស្រោបលេះដូងនាងឱ្យរងាក្នុងសុបិនរាត្រីដ៏សែនអាក្រក់៕